រូបថត៖ Andreas Nilsson

Stig កើតឆ្នាំ១៩៣៨

ពេលវេលាកន្លងទៅជាច្រើនឆ្នាំនៅសាលាទើបខ្ញុំបានចាប់ផ្តើមដឹងខ្លួនថា ព្រះអើយ! ខ្ញុំមិនដូចក្មេងប្រុសដទៃទៀតទេ។ ដូច្នេះ ខ្ញុំបានចាប់ផ្តើមដើរជាមួយក្មេងស្រីៗជំនួសវិញ ហើយត្រូវបានក្មេងប្រុសៗនិយាយចំអន់ឲ្យ។

មានកន្លែងមួយឈ្មោះថា Centralbadet គឺជាកន្លែងហែលទឹកសាធារណៈមួយ។ ពេលនោះ គេបែងចែកជាផ្នែកហែលទឹកបុរស និងនារី។ នៅពេលដែលខ្ញុំបានទៅទីនោះជាមួយបងប្អូនប្រុសរបស់ខ្ញុំ ខ្ញុំបានឃើញបុរសទាំងនោះខ្លួនទទេ។ ដោយសារទីនោះគ្មានមនុស្សស្រី ពួកគេលែងខ្លួនទទេទាំងអស់គ្នា។ ខ្ញុំគិតថា វាគួរឲ្យចាប់ចិត្តខ្លាំងណាស់! ដូច្នេះ ពេលក្រោយខ្ញុំបានទៅកន្លែងនោះដោយផ្ទាល់។ គឺមានអ្វីម្យ៉ាងជំរុញខ្ញុំទៅទីនោះ។ ប្រាកដណាស់ គឺមិនមែនដោយសារតែការហែលទឹកនោះទេ.... មិនមែនទេ។ ខ្ញុំបានចាប់ផ្តើមដឹងខ្លួនកាន់តែច្បាស់ថា ខ្ញុំពិតជាចាប់អារម្មណ៍នឹងរឿងនេះ។

ខ្ញុំក៏ត្រូវតែនិយាយផងដែរ ថាតើម្តាយរបស់ខ្ញុំបានលើកឡើងដូចម្តេចអំពីបញ្ហានេះ។ គាត់ធ្លាប់សួរថា៖ តើឯងចាប់អារម្មណ៍នឹងមនុស្សប្រុសមែនទេ? ហើយខ្ញុំបានឆ្លើយតបទៅវិញថា អត់ទេ ប្រាកដណាស់គឺអត់ទេ តើខ្ញុំអាចគិតអញ្ចឹងបានម្តេចទៅ? ប៉ុន្តែ នៅពេលមួយខ្ញុំបានមានអារម្មណ៍ថា៖ ទេ! ខ្ញុំមិនអាចធ្វើអញ្ចឹងតទៅទៀតបានទេ។ ដូច្នេះ ក្រោយមក នៅពេលគាត់បានសួរខ្ញុំម្តងទៀត ខ្ញុំបានឆ្លើយថា៖ បាទ! ខ្ញុំចាប់អារម្មណ៍នឹងមនុស្សប្រុសមែន! បន្ទាប់ពីនោះមក គាត់បានចាប់ផ្តើមរិះរកមធ្យោបាយធ្វើយ៉ាងណាដើម្បីអាច «កែតម្រូវ» បញ្ហានេះបាន

ព្រោះគាត់បានគិតថាវាគឺជាជំងឺមួយ។ ហើយនៅពេលនោះ វាត្រូវបានទុកជាផ្លូវការថាជាជំងឺមួយ។ គាត់បានស្នើឲ្យខ្ញុំទៅជួបគ្រូពេទ្យផ្លូវចិត្តដើម្បីទទួលការព្យាបាល ហើយខ្ញុំបានគិតថា យល់ព្រម ខ្ញុំនឹងធ្វើអញ្ចឹង វាមិនខុសទាស់អីទេ។ ហើយយើងបានសន្ទនាគ្នាយ៉ាងល្អ។ ពេលចុងក្រោយនេះ ម្តាយខ្ញុំត្រូវបានស្នើឲ្យទៅជាមួយផងដែរ ហើយគ្រូពេទ្យបានប្រាប់គាត់ថា គាត់គួរមានមោទនភាព និងរីករាយដែលមានកូនប្រុសមានសុខភាពល្អ និងមាំមួនបែបនេះ។ ប៉ុន្តែ គាត់បានបដិសេធចំពោះមតិនេះ ដោយនិយាយថា៖ ទេ! វានៅក្មេង និងជាអ្នកបន្តពូជ គ្មាននរណាត្រូវពឹងពាក់ទេ។ ក្រោយមក គាត់បែរជាបានប្រាប់ខ្ញុំថា គាត់រកបានកន្លែងមួយនៅប្រទេសប៉ូឡូញ ដែលនៅទីនោះមានអណ្តូងរ៉ែអំបិល។ ប្រសិនបើ ឯងចំណាយពេលនៅក្នុងអណ្តូងរ៉ែអំបិលនោះ ឯងប្រហែលជាអាចទទួលបាន «ភាពសុទ្ធ» មកវិញ... ត្រង់ចំណុចនេះ ខ្ញុំបាននិយាយថា៖ ម៉ាក់! វាគ្រប់គ្រាន់ហើយ!

ទាំងអស់នេះទាក់ទងនឹងការតស៊ូដំបូងៗ។ ខ្ញុំមិនដែលចូលក្បួនដើរសម្តែងមតិ ឬធ្វើអ្វីមួយដូចនេះទេ។ ខ្ញុំមិនហ៊ានទេ ដោយសារតែខ្ញុំបានដឹងថា ប្រសិនបើប្រកាសថាខ្ញុំជាមនុស្សប្រុសស្រលាញ់ភេទដូចគ្នា ខ្ញុំនឹងត្រូវគេដកចេញពីតួនាទីជាគ្រូបង្រៀនរបស់ខ្ញុំជាមិនខាន។ ពេលមួយគត់ដែលខ្ញុំបានចូលរួមក្បួនដើរ គឺទិវាជំនួយពិភពលោក។ ពីព្រោះ Peter របស់ខ្ញុំបានឆ្លងជំងឺនៅឆ្នាំ១៩៨៩ រហូតដល់ឆ្នាំ១៩៩២ គាត់បានលាចាកលោកនេះទៅ។ កាលនោះ គ្មានអ្វីអាចព្យាបាលឲ្យជាសះស្បើយនោះទេ ទាំងអស់គ្នាដឹងថាគ្រប់គ្នានឹងស្លាប់។

ក្នុងទិវាជំនួយពិភពលោក យើងបានប្រមូលផ្តុំគ្នានៅ Sergel Torg ក្នុងទីក្រុងស្តុកខុល ហើយទៀននៅខាងក្រៅត្រូវបានដុតបំភ្លឺ និងដាក់នៅលើជណ្តើរក្នុងសួនច្បារសាធារណៈសម្រាប់អ្នកគ្រប់គ្នាដែលបានស្លាប់។ ពីមួយឆ្នាំទៅមួយឆ្នាំ ជណ្តើរទាំងនេះ កាន់តែពេញទៅៗ រហូតដល់ក្លាយជាសមុទ្រភ្លើង។ ខ្ញុំគិតថារឿង

នេះបានធ្វើឲ្យមនុស្សម្នាកាន់តែភ្លឺភ្នែក និងធ្វើឲ្យពួកគេដឹងថា តើជំងឺសាហាវប៉ុណ្ណា។